ថ្ងៃទី ៧ ខែមីនា ឆ្នាំ២០១៣

# សេចក្តីប្រកាសព័ត៌មាន

## របាយការណ៍សាកលបង្ហាញឱ្យឃើញថា ចំណាត់ថ្នាក់តម្លាភាពថវិកាកម្ពុជា ស្ថិតក្នុងចំណោមប្រទេសដែលមានកម្រិតទាបបំផុតលើពិភពលោក ប៉ុន្តែ ការកែលម្អអាចប្រព្រឹត្តទៅបាន ជាមួយនឹងចំណាយតិចតួចប៉ុណ្ណោះ

ថ្ងៃនេះ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ក្នុងការសហការជាមួយ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន អង្គការអុកស្វាម និងអង្គការតម្លាភាពកម្ពុជា ធ្វើការផ្សព្វផ្សាយលទ្ធផលនៃអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា (Open Budget Survey – OBS) ឆ្នាំ២០១២ អំពីចំណាត់ថ្នាក់តម្លាភាពថវិការបស់ប្រទេសកម្ពុជា។ អង្កេតនេះបង្ហាញថា ប្រទេសកម្ពុជាបានទទួលពិន្ទុ ១៥ លើ ១០០ ដូចដែលកម្ពុជាបានទទួលកាលពីឆ្នាំ ២០១០។

ប្រៀបធៀបនឹងប្រទេសជិតខាង និងបណ្តាប្រទេសអាស៊ីអគ្នេយ៍ឯទៀត ដែលបានចូលរួមក្នុងអង្កេតនេះ ពិន្ទុរបស់ប្រទេសកម្ពុជាគឺស្មើនឹងពាក់កណ្តាល នៃពិន្ទុមធ្យមតំបន់ ៣២ និងទាបជាងខ្លាំងធៀបនឹងពិន្ទុមធ្យមសាកល ៤៣។

អង្កេតOBS គឺជា គំនិតផ្តួចផ្តើមមួយរបស់អង្គការភាពជាដៃគូនៃថវិកាអន្តរជាតិ (International Budget Partnership - IBP) និងជាអង្កេតសាកលធ្វើឡើងរៀងរាល់ពីរឆ្នាំម្តង ដែលផ្តល់នូវការវាស់ស្ទង់អំពីកម្រិតតម្លាភាព និងគណនេយ្យភាពនៃថវិកានៅជុំវិញពិភពលោកតែមួយគត់ដែលមានលក្ខណៈឯករាជ្យ អាចប្រៀបធៀបបាន និងទៀងទាត់។ អង្កេតនេះគឺជាការបង្ហាញពីតថភាពជាក់ស្តែងនៃតម្លាភាព គណនេយ្យភាព និងការចូលរួមរបស់សាធារណជន នៅក្នុងដំណើរការថវិកាជាតិ។

អង្កេតOBS ធ្វើការវាយតម្លៃថា តើរដ្ឋាភិបាលថ្នាក់ជាតិបានផ្សព្វផ្សាយជាសាធារណៈនូវឯកសារថវិកាសំខាន់ៗចំនួនប្រាំបីដែរឬទេ និងដោយរបៀបណា ហើយថា តើព័ត៌មានដែលមាននៅក្នុងឯកសារទាំងនោះ មានលក្ខណៈគ្រប់ជ្រុងជ្រោយទាន់ពេលវេលា និងមានសារៈប្រយោជន៍ចំពោះសាធារណជនដែរឬយ៉ាងណា។ ទន្ទឹមនឹងនេះ អង្កេតក៏វាយតម្លៃផងដែរទៅលើវិសាលភាពនៃការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូល ក៏ដូចជាឱកាសដែលសាធារណជនអាចចូលរួមបាននៅក្នុងដំណើការថវិកាជាតិ។

"យើងពិតជាសង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជានឹងពិចារណាលទ្ធផលទាំងនេះ និងធ្វើការកែតម្រូវស្ថានភាពនេះ ដោយផ្សព្វផ្សាយជាសាធារណៈនូវឯកសារថវិកាសំខាន់ៗឯទៀតដែលមិនទាន់បានផ្សព្វផ្សាយនៅឡើយ ពិសេសគឺសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ របាយការណ៍ពាក់កណ្តាលឆ្នាំ និងរបាយការណ៍សវនកម្ម ឲ្យបានទាន់ពេលវេលា និងបានទៀងទាត់។ ការងារនេះអាចធ្វើទៅរួចដោយចំណាយតិចតួច ឬក៏មិនមានចំណាយបន្ថែមឡើយ ហើយការផ្សព្វផ្សាយឯកសារទាំងនេះនឹងបង្កើនឱកាសឲ្យមានការចូលរួមពីសាធារណជនក្នុងដំណើរការថវិកាជាតិ និងឈានទៅកាន់សង្គមមួយដែលទទួលបានព័ត៌មានកាន់តែច្រើន" នេះជាប្រសាសន៍លោក ឈិត សំអាត នាយកប្រតិបត្តិនៃ វេទិកាអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។

គាត់បានបន្តថា "ការធ្វើបែបនេះក៏នឹងបង្ហាញពីការអនុវត្តនូវការតាំងចិត្ត និងកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ"។

ឯកសារថវិកាទាំងប្រាំបី រួមមាន របាយការណ៍បុរេថវិកា សេចក្តីព្រាងច្បាប់ថវិការបស់រដ្ឋាភិបាល ច្បាប់ថវិកាដែលបានអនុម័ត ថវិកាសម្រាប់ប្រជាពលរដ្ឋ របាយការណ៍ក្នុងឆ្នាំ របាយការណ៍ពាក់កណ្តាលឆ្នាំ របាយការណ៍ដំណាច់ឆ្នាំ និងរបាយការណ៍សវនកម្ម។

ក្នុងចំណោមឯកសារទាំងប្រាំបីនេះ ប្រទេសកម្ពុជាផលិត និងផ្សព្វផ្សាយឯកសារចំនួនបួនជាសាធារណៈ។ ឯកសារទាំងនោះរួមមាន របាយការណ៍បុរេថវិកា ច្បាប់ថវិកាដែលបានអនុម័ត របាយការណ៍ក្នុងឆ្នាំ និងរបាយការណ៍ដំណាច់ឆ្នាំ។ ប៉ុន្តែនៅមានបញ្ហាពាក់ព័ន្ធនឹងភាពទាន់ពេលវេលា និងភាពពិស្តារនៃព័ត៌មាន យ៉ាងហោចណាស់នៅក្នុងឯកសារពីរ នៃឯកសារទាំងបួន។ ឧទាហរណ៍ របាយការណ៍ដំណាច់ឆ្នាំ គឺផ្សព្វផ្សាយនៅខែមាសទីពីរនៃឆ្នាំសារពើពន្ធបន្ទាប់ ហើយទម្រង់នៃចំណាត់ថ្នាក់ថវិកាដែលប្រើប្រាស់នៅក្នុងឯកសារនេះ នៅខ្វះសង្គតិភាពជាមួយនឹងទម្រង់ដែលប្រើប្រាស់នៅក្នុងឯកសារថវិកាសំខាន់ៗដទៃទៀត។

នៅកម្ពុជា ឯកសារបីក្នុងចំណោមឯកសារថវិកាចំបងៗ ពោលគឺ សេចក្តីព្រាងច្បាប់ថវិកា របាយការណ៍ពាក់កណ្តាលឆ្នាំ និងរបាយការណ៍សវនកម្ម ត្រូវបានផលិត ប៉ុន្តែមិនទាន់បានផ្សព្វផ្សាយនៅឡើយ។ ទន្ទឹមនឹងនេះ ប្រទេសកម្ពុជាក៏មិនផលិតឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋដែរ។ ឯកសារទាំងនេះ មានសារៈសំខាន់ជាខ្លាំងក្នុងការបង្កើនឱកាសឲ្យសាធារណជន ចូលរួមក្នុងដំណើរការថវិកា និងទាមទារឲ្យរាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះការគ្រប់គ្រងប្រាក់កាសសាធារណៈ។

ថវិកាប្រជាពលរដ្ឋ គឺជាទម្រង់សាមញ្ញនៃច្បាប់ថវិកាប្រចាំឆ្នាំ ហេតុដូច្នេះវាជាឯកសារដ៏មានសារៈសំខាន់មួយជំនួយឲ្យសាធារណជនងាយយល់អំពីផែនការថវិការបស់រាជរដ្ឋាភិបាល។

លោកសំអាត បានមានប្រសាសន៍ថា "សារៈសំខាន់នៃឯកសារនេះ ត្រូវបានប្រទេសជិតខាងរបស់យើងនៅក្នុងតំបន់ទទួលស្គាល់ជាខ្លាំង ពិសេសនៅប្រទេសឥណ្ឌូនេស៊ី និងប្រទេសថៃ។ នៅប្រទេសឥណ្ឌូនេស៊ី ការផ្សព្វផ្សាយនូវថវិកាប្រជាពលរដ្ឋនេះ បានរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនពិន្ទុនៃការផ្សព្វផ្សាយពត៌មានថវិកា ហើយជួយលើកស្ទួយប្រទេសនេះឲ្យចាកចេញពីក្រុមប្រទេសផ្តល់ "ព័ត៌មានមួយចំនួន" ទៅកាន់ក្រុមប្រទេសដែលផ្តល់ "ព័ត៌មានច្រើន"។ ប្រទេសកម្ពុជាក៏អាចសម្រេចបាននូវវឌ្ឍនភាពដូចគ្នានេះដែរ ប្រសិនបើរាជរដ្ឋាភិបាលពិចារណាអំពីការបោះផ្សាយឡើងវិញនូវ "ថវិកាសង្ខេប" ដែលធ្លាប់ត្រូវបានបោះផ្សាយម្តងនៅក្នុងឆ្នាំ២០០៧ នោះ"។

ដូចដែលអង្កេតនេះបានបង្ហាញ ឥទ្ធិពលរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូលរបស់ប្រទេសកម្ពុជា គឺមានកម្រិត "បង្គួរ" ខណៈដែលនៅប្រទេសជិតខាងរបស់កម្ពុជា លើកលែងប្រទេសភូមា ឥទ្ធិពលនៃស្ថាប័ននីតិប្បញ្ញត្តិគឺមានកម្រិត "បង្គួរ" និង "ខ្លាំង" ហើយស្ថាប័នសវនកម្មកំពូលវិញគឺមានឥទ្ធិពល "ខ្លាំង"។ លើសពីនេះទៀត ឱកាសសម្រាប់ការចូលរួមជាសាធារណៈនៅក្នុងដំណើរការថវិកាជាតិនៅកម្ពុជាគឺ នៅតិចតួចនៅឡើយ។

"យើងមិនឃើញមានភាពស្មុគស្មាញផ្នែកបច្ចេកទេសធំដុំឡើយ ក្នុងការរាំងស្ទះប្រទេសកម្ពុជាមិនឲ្យទទួលបានពិន្ទុតម្លាភាពថវិការបស់ខ្លួនខ្ពស់ជាងនេះ។ អ្វីដែលគេត្រូវការ គឺឆន្ទៈនយោបាយពិតប្រាកដពីថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ដែលត្រូវអមដោយសកម្មភាពជាក់ស្តែង ដើម្បីលើកកម្ពស់តម្លាភាពនៅក្នុងដំណើរការថវិកាទាំងមូល ហើយបើកចំហឲ្យសង្គមស៊ីវិលបានចូលរួម និងគាំទ្រក្នុងការសម្រេចបាននូវការងារនេះ" នេះជាប្រសាសន៍លោក ព្រាប កុល នាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជា។

លោកបានបន្តទៀតថា "តម្លាភាព និងភាពបើកចំហគឺជា មូលដ្ឋានគ្រឹះសម្រាប់សង្គមប្រជាធិបតេយ្យ ដែលនាំមកនូវទំនុកចិត្ត និងបង្កើតឲ្យមាននូវភាពស្របច្បាប់។ ខណៈដែលប្រទេសកម្ពុជា បានជ្រើសយកមាគ៌ាប្រជាធិបតេយ្យ ថ្នាក់ដឹកនាំកម្ពុជាត្រូវគោរពឲ្យបានម៉ឺងម៉ាត់ចំពោះគុណតម្លៃ និងគោលការណ៍ទាំងនេះ សម្រាប់ជាប្រយោជន៍ដល់ពលរដ្ឋរបស់ខ្លួន និងដើម្បីលើកកម្ពស់មុខមាត់ប្រទេសកម្ពុជា នៅលើឆាកអន្តរជាតិ"។

លោក ណែប ស៊ីនថៃ នាយក វិទ្យាស្ថានឥស្សរមតិ និងគោលនយោបាយ បាននិយាយថា "ការបើកចំហរបស់រដ្ឋាភិបាល និងថវិកាជាតិរបស់ខ្លួន លទ្ធភាពទទួលបានព័ត៌មាន និងអ្វីដែលគេហៅថាសិទ្ធិក្នុងការដឹង និងសិទ្ធិក្នុងការទទួលបានព័ត៌មានរបស់ពលរដ្ឋម្នាក់ៗ គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់ក្នុងការជម្រុញឲ្យមានការចូលរួមជាសាធារណៈក្នុងការលើកកម្ពស់តម្លាភាពថវិកា"។

លោក វ៉ារិន ក្រាហ្វឈីក នាយក អង្គការភាពជាដៃគូនៃថវិកាអន្តរជាតិ បានបញ្ចេញមតិថា "សេចក្តីសម្រេចចិត្ត និងដំណើរការថវិកាមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយបញ្ហាជាច្រើន ក្នុងចំណោមបញ្ហាបន្ទាន់ៗបំផុតនៅក្នុងពិភពលោក"។

"ជោគជ័យនៃកិច្ចប្រឹងប្រែងដូចជា ការប្រឹងប្រែងកាត់បន្ថយអត្រាស្លាប់របស់មាតា ការលុបបំបាត់ភាពក្រីក្រដែលនៅតែបន្ត ការផ្តល់លទ្ធភាពឲ្យកុមារទាំងអស់បានទទួលនូវការអប់រំដែលមានគុណភាព និងការដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ជាដើម ពឹងផ្អែកទាំងស្រុងទៅលើប្រការដែលថា តើប្រទេសនានាធ្វើសេចក្តីសម្រេចចិត្តស្តីពីថវិកាបានត្រឹមត្រូវដែរ ឬយ៉ាងណា ហើយតើសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពដែរឬទេ។ ទាំងអស់នេះ គឺលើសពីបញ្ហាអភិបាលកិច្ច ដែលមានលក្ខណៈអរូបីទៅទៀត។ គឺវាទាក់ទងទៅនឹង គុណភាពនៃជីវិតរបស់មនុស្សរាប់លាននាក់នៅជុំវិញពិភពលោក"។

ផ្អែកលើលទ្ធផលនៃអង្កេតខាងលើ អង្គការសង្គមស៊ីវិលសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាសូម៖

- ចាត់វិធានការជាបន្ទាន់ ក្នុងការផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកា របាយការណ៍ពាក់កណ្តាលឆ្នាំ និងរបាយការណ៍សវនកម្ម ឲ្យបានទាន់ពេលវេលា និងទៀងទាត់ នៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ផលិត និងផ្សព្វផ្សាយថវិកាប្រជាពលរដ្ឋ (ថវិកាសង្ខេប)
- បង្កើនភាពគ្រប់ជ្រុងជ្រោយ នៃរបាយការណ៍បុរេថវិកា របាយការណ៍ក្នុងឆ្នាំ និងរបាយការណ៍ដំណាច់ឆ្នាំ
- ចាត់វិធានការជាក់ស្តែងឆ្ពោះទៅពង្រីកការចូលរួមរបស់សាធារណជន ដោយអនុញ្ញាតឲ្យសាធារណជនធ្វើជាកសិណសាក្សី នៅក្នុងសវនាការរបស់ស្ថាប័ននីតិប្បញ្ញត្តិ ឬក្នុងការពិភាក្សានានាអំពីថវិកា - ដោយបង្កលក្ខណៈឲ្យស្ថាប័ននីតិប្បញ្ញត្តិអាចអនុវត្តការត្រួតពិនិត្យបានកាន់តែប្រសើរឡើងលើដំណើរការថវិកា - និងដោយពង្រឹងអំណាចរបស់អាជ្ញាធរសវនកម្មជាតិ តាមរយៈការបង្កើនថវិកា និងតាក់តែងច្បាប់ថវិការបស់អាជ្ញាធរនេះ ដែលត្រូវកំណត់ដោយអង្គនីតិប្បញ្ញត្តិ ឬតុលាការ។

**ទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ៖**


| | | | |
|---|---|---|---|
| លោក ឈិត សំអាត | នាយកប្រតិបត្តិ | វេទិកាអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា | 012 928 585 |
| លោក ព្រាប កុល | នាយកប្រតិបត្តិ | អង្គការតម្លាភាព កម្ពុជា | 012 877 833 |
| លោក ណែប ស៊ីនថៃ | នាយក | វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ | 012 527 004 |
| លោក ឆាយ សារ៉ាត | នាយកប្រតិបត្តិ | សម្ព័ន្ធភាពកម្ពុជាដើម្បីតម្លាភាពចំណូលធនធាន | 012 589 958 |
| លោក ស៊ាង សុលក្ខណ៍ | មន្ត្រីទំនាក់ទំនងប្រចាំតំបន់ | អង្គការអុកស្វាមប្រចាំតំបន់អាស៊ីខាងកើត | 012 356 389 |